# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៣

## ជប៉ុនផ្តល់១២២,៧៧១ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សា



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ១២២,៧៧១ដុល្លារអាមេរិក ដល់មន្ទីរអប់រំ យុវជន និង កីឡាខេត្តបាត់ដំបង សម្រាប់គម្រោងសាងសង់អគារសិក្សានៅសាលាបឋមសិក្សាយុត្តិធម៌ និង សាលាបឋមសិក្សាសំណាងព្រះស្រីក្នុងស្រុកបវេល ខេត្ត បាត់ដំបង។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយលោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ ភារៈធារីស្តីទីស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក ងី សែត ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបងនៅស្ថានទូតជប៉ុន។





ដើម្បីកែលម្អបរិស្ថានអប់រំ មន្ទីរ អប់រំ យុវជន និង កីឡាខេត្តបាត់ដំបងនឹងអនុវត្តគម្រោងសាងសង់អគារសិក្សាថ្មី ដោយ មានបំពាក់បរិក្ខារសិក្សាផងនៅសាលាបឋមសិក្សាយុត្តិធម៌ និង សាលាបឋមសិក្សាសំណាងព្រះស្រីក្នុងបវេល ខេត្ត បាត់ដំបង។ ជាផ្នែកមួយក្នុងគម្រោងនេះដែរ បង្គន់អនាម័យ និង អាងស្តុកទឹកក៏នឹងត្រូវបានសាងសង់ផងដែរ។ យើងរំពឹងថា សិស្សា នុសិស្សប្រមាណ៧៨០នាក់នៅសាលាបឋមសិក្សា ទាំងពីរនេះនឹងទទួលបានការអប់រំកាន់តែប្រសើរដោយសារការកែលម្អបរិស្ថានអប់រំនេះ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណេ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និង ស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង ភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការ ចិញ្ចឹមជីវិត និង សេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជា ជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកា ជាង ៤៨.៧ លានដុល្លាអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៨៦ គម្រោង នៅទូទាំង ប្រទេស។



ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០
អ៊ីមែល: eco.jpn@.pp.mofa.go.jp
គេហទំព័រ: http://www.kh.emb-japan.go.jp